ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សូមគោរពជម្រាបជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ឯកឧត្តមបណ្ឌិតជាទីគោរពរាប់អាន

ដូចដែល ឯកឧត្តមបណ្ឌិត បានជ្រាបរួចមកហើយថា មានកិច្ចប្រជុំមួយនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយខាងសហព័ន្ធទេសចរណ៍កម្ពុជា ដែលដឹកនាំដោយមេចុងភៅ លូ ម៉េង ដែលលោកជាសហប្រធានខាងវិស័យឯកជននៃក្រុមការងារលើវិស័យទេសចរណ៍។ គោលបំណងនៃកិច្ចប្រជុំនោះ គឺដើម្បីបង្ហាញនូវធាតុសកម្មសម្រាប់សុំឲ្យរាជរដ្ឋាភិបាលធ្វើការពិចារណាដើម្បីជួយដល់វិស័យទេសចរណ៍ឲ្យរស់រានបានក្នុងខណៈពេលដ៏លំបាកនេះ។ (របៀបវារៈភ្ជាប់) ខ្ញុំបាទមានសេចក្តីរីករាយក្នុងការរាយការណ៍ថា នោះជាកិច្ចប្រជុំក្រុមការងារមួយ និងដោយមេត្រីភាព។ ខ្ញុំបាទត្រូវបានអញ្ជើញឲ្យចូលរួមកិច្ចប្រជុំ មិនមែនដោយសារខ្ញុំបាទស្ថិតនៅក្នុងវិស័យទេសចរណ៍នោះទេ ប៉ុន្តែក្នុងនាមខ្ញុំបាទជាប្រធានសភាពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជា និងជាសហប្រធានក្រុមការងារខាងផ្នែកច្បាប់ ពន្ធ និងអភិបាលកិច្ច របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ខ្ញុំបាទរីករាយណាស់ដែលបានចូលរួមកិច្ចប្រជុំក្នុងការគាំទ្រនូវគំនិតផ្តួចផ្តើមរបស់សហព័ន្ធទេសចរណ៍កម្ពុជា។ ខ្ញុំបាទប្រាកដក្នុងចិត្តថា ឯកឧត្តមបណ្ឌិត បានជ្រាបរួចមកហើយថា ឧស្សាហកម្មទេសចរណ៍ រួមជាមួយផ្នែកទាំងអស់នៃវិស័យនេះត្រូវបានរងនូវផលប៉ះពាល់ភ្លាមៗ និងយ៉ាងខ្លាំងដោយ ជម្ងឺរាតត្បាតជាសកលលោក ហើយសាកសមទទួលបានការគាំទ្រពីយើងទាំងអស់គ្នា។ នៅថ្ងៃណាមួយពេលដែលវិបត្តិនៃសកលលោកនេះត្រូវបានបញ្ចប់ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរបស់វិស័យទេសចរណ៍នេះ។

ថ្ងៃនេះ ខ្ញុំបាទសរសេរលិខិតនេះជូន ឯកឧត្តមបណ្ឌិត ដើម្បីស្នើសុំចំណាប់អារម្មណ៍ និងការគាំទ្រពី ឯកឧត្តមបណ្ឌិត សម្រាប់ពង្រីកបន្ថែមនូវអត្ថប្រយោជន៍ដែលបានស្នើសុំដោយសហព័ន្ធទេសចរណ៍កម្ពុ

**International Business Chamber of Cambodia**
3rd floor, #23, St. 139, Sangkat Veal Vong,
Khan 7 Makara, Phnom Penh, Kingdom of Cambodia
Tel: 023 964 455, 089 720 008
E-Mail: info@ibccambodia.com, Website: www.ibccambodia.com

ជាដល់ វិស័យផ្សេងៗទៀត និងប្រសិនបើអាចអនុវត្តបានចំពោះសហគមន៍អាជីវកម្មទាំងមូល។ បើទោះបីជាផលប៉ះពាល់លើវិស័យទេសចរណ៍ជារឿងបន្ទាន់ក៏ដោយ តែជាការពិត សេដ្ឋកិច្ចទាំងមូលកំពុងរងគ្រោះដោយសារជម្ងឺរាតត្បាត វីរុសកូរ៉ូណា នេះ។ រាល់អាជីវកម្មទាំងអស់នៅទីនេះនឹងទទួលរងនូវផលប៉ះពាល់មួយចំនួន ដូច្នេះជំនួយក៏គួរតែត្រូវបានពង្រីកបន្ថែមឲ្យដល់ពួកគេផងដែរ។ ដូចនេះ ក្នុងនាមតំណាងឲ្យសមាជិកទាំងអស់របស់សភាពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជា និងក្រុមការងារ " ឃ " ខ្ញុំបាទសូមស្នើសុំឲ្យ ឯកឧត្តមបណ្ឌិត និងក្រុមការងាររបស់ ឯកឧត្តម ពិចារណាអំពីអត្ថប្រយោជន៍ស្រដៀងគ្នានេះដើម្បីឲ្យបានពង្រីកបន្ថែមទៅដល់វិស័យផ្សេងៗទៀត និងសហគមន៍អាជីវកម្មជាទូទៅ។

សូមអរគុណចំពោះការពិចារណារបស់ ឯកឧត្តមបណ្ឌិត។

សូម **ឯកឧត្តម** មេត្តាទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០

ហត្ថលេខា

**ប្រេតតុន ស្កាវ៉ូនី**

សហប្រធានក្រុមការងារ "ឃ" តំណាងវិស័យឯកជន

ប្រធានសភាពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជា

បានឃើញដោយ

ឯកឧត្តម **ផាន់ ផល្លា**

អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**International Business Chamber of Cambodia**
3rd floor, #23, St. 139, Sangkat Veal Vong,
Khan 7 Makara, Phnom Penh, Kingdom of Cambodia
Tel: 023 964 455, 089 720 008
E-Mail: info@ibccambodia.com, Website: www.ibccambodia.com